- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១.-

តែងតាំង:

- ឯកឧត្តម រស់ រឿន ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានឋានៈស្មើអនុរដ្ឋលេខាធិការ
- ឯកឧត្តម ថាច់ សែម ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានឋានៈស្មើអនុរដ្ឋលេខាធិការ
- ឯកឧត្តម ណុប លាន ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានឋានៈស្មើអនុរដ្ឋលេខាធិការ
- ឯកឧត្តម កែរ សុខសិទ្ធិនី ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានឋានៈស្មើអនុរដ្ឋលេខាធិការ
- ឯកឧត្តម ម៉ុត ចន្ទ័ដារាវុទ្ធិ ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានឋានៈស្មើអគ្គនាយក
- ឯកឧត្តម ហួន ជីម៉ុងគៅហ្វើលីប ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានឋានៈស្មើអគ្គនាយក

មាត្រា ២.-

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសប់បន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៩៧. ០៤.០៨.២០០៤

លេខ: ១៦៧ ចរ

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/២០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវ ដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា១ .-**

តែងតាំងឯកឧត្តម ស៊េ គង់ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២ .-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៤*

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ក.ល.០៤.០៨.២០៥ លេខ ១៦៥ ចល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវ៉ន ឆាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/ ៧០៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស ,អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រី ០២ រូប នៃក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានរាយនាមខាងក្រោម ៖

១_ឯកឧត្តម ជួប សំអាត ជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល_ហិរញ្ញវត្ថុ ។

២_ឯកឧត្តម ជាម និមល ជាអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១២ ខែ សីហា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣រ.ល.០៤.០៨.៧០៦

លេខៈ [illegible] ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៧ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨០៤ /២០៦

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៦/៩៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងឯកឧត្តម ម៉ាន់ ចាំរឿន ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែ សីហា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៤.០៨.២០៧

លេខ ១៦៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២០៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **នុត បុតិណ្ណារ៉ា** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក**

២- ឯកឧត្តម **ជា យុតា** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក**

៣- ឯកឧត្តម **យីម ស្រ៊ីជា** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក**

៤- ឯកឧត្តម **ហាក់ សុខហៃ** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក**

៥- ឯកឧត្តម **អៀង សីវង្ស** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក**

៦- ឯកឧត្តម **សោម សុទុន្ស៊ី** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អគ្គនាយក**

៧- ឯកឧត្តម ខេង សិទ្ធិគុណ ជាជំនួយការសម្ដេចនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក

**មាត្រា ២.-**

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រស.០៤.០៨.២០៤

លេខ: ១៥៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ [illegible] ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឧកាឌី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/៧១០

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០១០០/០០៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០០/១២៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការតែងតាំង និងតំកល់ទុកអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

# ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានតែងតាំងសមាសភាពថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ហុង ស៊ុនហួត** | ទេសរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **នុត សុខុម** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម **ម៉ម ប៊ុនហេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤-ឯកឧត្តម **លី ប៉ូរ** | អនុប្រធានប្រចាំការ មានឋានៈស្មើរដ្ឋលេខាធិការ | |
| ៥-ឯកឧត្តម **អ៊ឹង ទុន្នី** | អនុប្រធាន មានឋានៈស្មើរដ្ឋលេខាធិការ ។ | |

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ .-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣៩៧.០៦.០៨.២១១

លេខៈ ១៦៧ ចប

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២១១

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្តទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេច ហេង សំរិន ប្រធានរដ្ឋសភាស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា

## <u>ត្រាស់បង្គាប់</u>

**មាត្រា ១.-** តែងតាំងឯកឧត្ដម **ម៉ែន ថុល** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សំរាប់អាណត្តិថ្មី ។

**មាត្រា ២.-** ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋ ស្ដីទី**

**ជា ស៊ីម**

៣៧.០៤.០៨.២១២

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/៧១៤

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត ចិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេច ជា ស៊ីម ប្រមុខរដ្ឋស្ដីទី

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានបញ្ចប់អាណត្តិទីប្រឹក្សា និងមន្ត្រីខុទ្ទកាល័យរបស់សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ដែលមានរាយនាមដូចខាងក្រោម :

ក_ទីប្រឹក្សា:

១-ឯកឧត្តម ស្នួង ម៉េងគា ២-ឯកឧត្តម លី ណារុន
៣-ឯកឧត្តម ថៃ ម៉ិនឈឿន ៤-ឯកឧត្តម សំ ហ៊ាង
៥-ឯកឧត្តម សៅ សេរីមុន្នី ៦-ឯកឧត្តម តូច ចាន់កុសល
៧-ឯកឧត្តម លី ប្រុស ៨-ឯកឧត្តម សួង ឥសាន

ខ_មន្ត្រីខុទ្ទកាល័យ

១-ឯកឧត្តម ទៅ ស្រ៊ុន

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១៤ ខែ សីហា ឆ្នាំ ២០០៤

គួចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

កាល.០៤.០៨.៧១៣

លេខ ៦៧៣ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៨ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/ ៧១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

តែងតាំង

លោកស្រី សុភ័ក្ត្រ ថាវី

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ សីហា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាសបង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣៧៧.០៤.០៨.៧១៤

លេខៈ ១៧១ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៨ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សៅ ឌី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/៧១៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

## តែងតាំង

លោក ទ្រី ភារព

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ សីហា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និង តាមព្រះរាជបន្ទូលបង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រាជ.០៤.០៨.៧១៥

លេខ ១៧០ - ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ធាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២១៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ខៀត ស៊ីសូដា** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៤.០៨.២១៦

ធ្វើនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៤

លេខៈ ៦៥៨ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ... ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណារី គាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់ឧស្សាហកម្ម សួយ ឆេង "SUOY CHHENG"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១:** បង្កើតតំបន់ឧស្សាហកម្មឈ្មោះ **សួយ ឆេង** "SUOY CHHENG" ដែលវិនិយោគដោយក្រុមហ៊ុន SUOY CHHENG INVESTMENT CO., LTD. មានទីតាំងស្ថិតនៅ *ភូមិនាងកុក, ឃុំប៉ាក់ខ្លង, ស្រុកមណ្ឌលសីមា, ខេត្តកោះកុង* (ជាប់តំបន់ឧស្សាហកម្មនាងកុក ដែលកំណត់ដោយអនុក្រឹត្យលេខ ១០អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២) ទំហំ១២៧ហិកតា ៦.៨២៤ម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងដី-ព្រំប្រទល់-ភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់នៃអនុក្រឹត្យនេះ។

**មាត្រា២:** ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់ឧស្សាហកម្ម នឹងត្រូវស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទបញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - អភិបាលខេត្តកោះកុង និងក្រុមហ៊ុន SUOY CHHENG INVESTMENT CO.,LTD. ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**ចម ប្រសិទ្ធ**

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :៤៦១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការផ្ទេរភារកិច្ច និង តែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យ លេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

### សម្រេច

**មាត្រា ១ :-**

ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចមានរាយនាមខាងក្រោម :

១- តែងតាំងលោក **គន បូរ៉ាមី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ
ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

២- ផ្ទេរលោក **ជ្រួន សុផល** ពីប្រធាននាយកដ្ឋាន នីតិកម្មអប់រំនិងបង្ការការពារ
មកជាប្រធាននាយកដ្ឋានអនុវត្តច្បាប់

៣- តែងតាំងលោក **ស នារិទ្ធ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននីតិកម្មអប់រំ និងបង្ការការពារ
ជាប្រធាននាយកដ្ឋាននីតិកម្មអប់រំ និងបង្ការការពារ

**មាត្រា ២ :-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤*

ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៤៦៧...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

~~~~~~~~~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា"

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា " អាជ្ញាធរអប្សរា "

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១** .-

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២ រូប នៅអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាដូចតទៅ :

១-លោកស្រី **ម៉ៅ ល្អ** ជាប្រធាននាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី១

២-លោក **ឃួន ឃុននាយ** ជាប្រធាននាយកដ្ឋានរមណីយដ្ឋាន និងបុរាណេវិទ្យាទី២
~~~~~~~~~

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ អគ្គនាយកអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១. -**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៤ គ្រឿង ជូនសប្បុរសជននៅក្នុង និង ក្រៅប្រទេស ដែលបានជួយកសាងសមិទ្ធផលនានាជាច្រើន លើវិស័យសិក្សាធិការ នៅក្នុងសាលាបឋមសិក្សាមេលប់ ស្ថិតនៅក្នុងឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដូចមានរាយ នាមខាងក្រោម ÷

១-លោក **KUBOTA MITSUAKI** ប្រធានសមាគម RISSHO KOSEIKAI ASHIKAGA YOUTH ប្រទេសជប៉ុន ថវិកាចំនួន ៣៥.១៤០ USD
២-លោក **YOSHIAKI SANADA** នាយកសកលវិទ្យាល័យ HOJU VOCATIONAL COLLEGE ប្រទេសជប៉ុន ថវិកាចំនួន ៣០.១៩០ USD
៣-លោក **ខ្វិក ទិជ័យ** សប្បុរសជនខ្មែររស់នៅប្រទេសជប៉ុន ថវិកាចំនួន ២៥.០០០ USD
៤-លោក **ជាង មុយឌុង** សប្បុរសជននៅខេត្តកណ្តាល ថវិកាចំនួន ១២.០០០ USD

**មាត្រា ២. -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ... ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៦៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

## សម្រេច

**មាត្រា ១.**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនមន្ត្រីប្រតិភូសហព័ន្ធអន្តរជាតិកាកបាទក្រហម អឌ្ឍច័ន្ទក្រហម ប្រចាំនៅកម្ពុជា ចំនួន ០២ រូប ដែលបានផ្តល់ថវិកា និង បច្ចេកទេសដ៏ថ្លៃថ្លា ជួយជំរុញអោយកាកបាទក្រហមកម្ពុជារីកចំរើន និង ទទួលបានជំនឿទុកចិត្តពីមតិជាតិ និង អន្តរជាតិ ដូចមានរាយនាមខាងក្រោម ÷

១-លោក **អង់តូនី ស្ប៉ាល់តុន** (Mr. Antony Spalton) ប្រធានប្រតិភូសហព័ន្ធអន្តរជាតិកាកបាទក្រហម អឌ្ឍច័ន្ទក្រហម

២-លោក **ខាណា បារ៉ាន់** (Mr. Kana Baran) ប្រតិភូអភិវឌ្ឍន៍ស្ថាប័ន

**មាត្រា ២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គលេខាធិការកាកបាទក្រហមកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា១.-**

ផ្លាស់លោកជំទាវ **សរ សោវន្ន** បច្ចុប្បន្ន អគ្គទីប្រឹក្សានៃគណៈប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ វិលចូលប្រទេសវិញ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

### សំរេច

**មាត្រា១.**

តែងតាំងលោក **សួន សាលីន** បច្ចុប្បន្ន ទីប្រឹក្សានៃគណៈប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ ជាអគ្គទីប្រឹក្សា។

**មាត្រា២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា ១ .-**

ត្រូវបានតែងតាំងមន្ត្រី ចំនួន ០២រូប នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា របស់ក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោម :

១- លោក **ឌុច ឆដ្ឋា** ជាអគ្គនាយករង
២- លោក **ប៊ូ ចណ្ណារិទ្ធ** ជាប្រធាននាយកដ្ឋានផលិតកម្មវិធីវិទ្យុ

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៤
នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥ សសរ

# សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ រហូតដល់សម្តេចអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៤៧...សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតអនុគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការចាត់តាំងសម្ដេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងសម្ដេចក្រុមព្រះ **នរោត្ដម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញសេចក្តីសម្រេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ ១ :** បង្កើតអនុគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលមានសមាសភាពដូចខាងក្រោម :

**ក. អនុគណៈកម្មការបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ :**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- | ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- | ឯកឧត្តម **ទ្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៤- | ឯកឧត្តម **អ៊ិត ប្រាំង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្តម **សុក ស៊ីផាន់ណារ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- | ឯកឧត្តម **ឡា ណារ៉ាត** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៧- | ឯកឧត្តម **នុត ណារ៉ាង** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- | ឯកឧត្តម **ច័ន្ទ គុងអ៊ីង** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | លេខាធិការ |

**ខ. អនុគណៈកម្មការកិច្ចសំរួលពាណិជ្ជកម្ម :**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- | ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤- | ឯកឧត្តម **ខ្លូត រ៉ាន់ឌី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | ឯកឧត្តម **តេង ឡៅ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦- | ឯកឧត្តម **អ៊ឹង គិរុន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៧- | ឯកឧត្តម **ជុំ អឿក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- | ឯកឧត្តម **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៩- | ឯកឧត្តម **ទៀ ជាង** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | លេខាធិការ |

គ. **អនុគណៈកម្មការសហគ្រាសធុនតូច-មធ្យម :**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ប្រធាន |
| ២- | ឯកឧត្តម **ទ័ខ នាយលាង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- | ឯកឧត្តម **យឹម ទឿនថន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤- | ឯកឧត្តម **អ៊ូ ម៉ុនឡុង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- | ឯកឧត្តម **ទោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៦- | លោកជំទាវ **អ៊ឹម ស៊ីថៃ** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ៧- | ឯកឧត្តម **សួន សិទ្ធី** | អគ្គលេខាធិការរង ក.អ.ក | សមាជិក |
| ៨- | លោក **ណោង សុធី** | អគ្គនាយក សភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ៩- | លោក **កែវ រតនៈ** | ប្រធាននាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម | លេខាធិការ |

ប្រការ ២ : អនុគណៈកម្មការនីមួយៗ មានភារកិច្ចរួម និងភារកិច្ចដោយឡែក ដូចខាងក្រោម :

ក. **ភារកិច្ចរួម :**

- លើកឡើងនូវវាលវិធានការចាំបាច់ ក្នុងក្របខ័ណ្ឌទទួលខុសត្រូវរបស់ខ្លួន ដើម្បីជំរុញការអនុវត្តន៍កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ពិសេសលើរាល់ចំណុចពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ផ្នែកឯកជន ។
- ពង្រឹងការអនុវត្តន៍គោលការណ៍ "អភិបាលកិច្ចល្អ" នៅតាមគ្រប់ផ្នែកដែលពាក់ព័ន្ធ ដល់ការងារធុរកិច្ច និងការងារវិនិយោគឯកជន
- ពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយដៃគូអភិវឌ្ឍន៍ ទាំងអ្នកផ្តល់ជំនួយ ទាំងវិនិយោគិន ទាំងធុរជន ដើម្បីលើកឡើងនូវផែនការសកម្មភាពតាមផ្នែកនីមួយៗ និងស្វែងរកប្រភពហិរញ្ញប្បទាន សំរាប់ជំរុញផែនការសកម្មភាពទាំងនោះ អោយមានដំណើរការជាក់ស្តែង និងមានប្រសិទ្ធភាព
- សហការពិភាក្សា ដើម្បីកំណត់គោលនយោបាយ និងលើកឡើងជាវិធានការដោះស្រាយ ក្នុងក្របខ័ណ្ឌអនុគណៈកម្មការទាំង៣ សំរាប់រាល់ករណីដែលមិនស្ថិតក្នុងការទទួលខុសត្រូវរបស់អនុគណៈកម្មការនីមួយៗ
- មានសិទ្ធិធ្វើការងារប្រទាក់ក្រឡាគ្នា ជាមួយក្រុមការងារតាមវិស័យ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដែលមានការពាក់ព័ន្ធ ។

ខ. **ភារកិច្ចដោយឡែក :**

ខ១- សំរាប់អនុគណៈកម្មការបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ

- លើកឡើងនូវវិធានការចាំបាច់ ប៉ារ៉ែអោយការពង្រឹងនិងកែលំអបរិស្ថានវិនិយោគ និងធុរកិច្ច

- លើកគោលនយោបាយលើកទឹកចិត្ត ព្រាង ឬ/និងពិនិត្យសេចក្តីព្រាងរាល់លិខិតបទដ្ឋាន សំរាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ
- រៀបចំបញ្ជីគំរោងហេដ្ឋារចនាសម្ព័ន្ធ គ្រប់ប្រភេទ ដែលទាមទារការចូលរួមពីសំណាក់ផ្នែកឯកជន

១២- <u>សំរាប់អនុគណៈកម្មការកិច្ចសំរួលពាណិជ្ជកម្ម</u>

- បន្ថយរាល់បែបបទស្មុគ្រស្មាញ និងវែងអន្លាយនៅតាមបណ្តាក្រសួង-ស្ថាប័ន ពាក់ព័ន្ធដល់ការនាំចូល-នាំចេញរបស់ក្រុមហ៊ុន
- បំបាត់ចោលនូវភារកិច្ចជាន់គ្នា របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួតពិនិត្យតែមួយកន្លែង អោយមានប្រសិទ្ធភាព
- ពង្រឹងការអនុវត្តន៍យន្តការ "**ច្រកចេញ-ចូលតែមួយ**" នៅតាមបណ្តាច្រកអន្តរជាតិ
- លើកឡើងនូវវិធានការចាំបាច់ បំរើអោយការអនុវត្តន៍ច្បាប់-បទបញ្ញត្តិនានា ចំពោះរាល់បាតុភាពអសកម្ម ប៉ះពាល់ដល់ការងារធុរកិច្ច

១៣- <u>សំរាប់អនុគណៈកម្មការសហគ្រាសធុនតូច-មធ្យម</u>

- លើកគោលនយោបាយលើកទឹកចិត្តចំពោះឧស្សាហកម្មផលិតទំនិញបំរើទីផ្សារក្នុងស្រុក ឬឧស្សាហកម្មផលិតទំនិញជំនួសការនាំចូល ដើម្បីឆ្លើយតបទៅនឹងសំណូមពរជាយុទ្ធសាស្ត្រ នៃការបង្កើតមូលដ្ឋានផលិតកម្មទំនិញក្នុងប្រទេសអោយបានច្រើន ពិសេសចំពោះមុខយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម
- កំណត់គោលនយោបាយលើកទឹកចិត្តនិងគាំទ្រសហគ្រាសធុនតូច-មធ្យម
- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួតប្រជែង សំរាប់សហគ្រាសធុនតូច-មធ្យម
- រៀបចំផែនការសកម្មភាព ជំរុញនិងគាំទ្រសហគ្រាសធុនតូច-មធ្យម ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្តន៍
- ជំរុញការរៀបចំបទបញ្ញត្តិនានា ស្តីពីការគ្រប់គ្រងសហគ្រាសធុនតូច-មធ្យម
- អនុវត្តតួនាទីផ្សេងទៀត ដែលពាក់ព័ន្ធដល់ការជំរុញ និងគាំទ្រសហគ្រាសធុនតូច-មធ្យម ។

<u>ប្រការ ៣</u> : ប្រធានអនុគណៈកម្មការ អាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធមកចូលរួមការងារបាន ក្នុងករណីចាំបាច់ ។ ពេលប្រធានអវត្តមាន អនុគណៈកម្មការនីមួយៗ នឹងត្រូវដឹកនាំការងារ ឬប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬតំណាង តាមការប្រគល់សិទ្ធិរបស់ប្រធាន ។

សមាសភាពទាំងអស់នៃអនុគណៈកម្មការនីមួយៗ មានសិទ្ធិចាត់តាំងរៀង១ខ្លួននូវសមាជិកបំរុង០១រូប សំរាប់ជួយការងារ ឬជំនួស នៅពេលអវត្តមាន ។

**ប្រការ ៤** : អនុគណៈកម្មការនីមួយៗ ត្រូវរាយការណ៍ជាប្រចាំ ជូនគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន អំពីរាល់សភាពការណ៍ ក៏ដូចជាវិធានការដែលបានដាក់ចេញ និងអំពីសំណូមពរដែលសុំការសំរេច ព្រមទាំងទិសដៅត្រូវអនុវត្តបន្ត។

**ប្រការ ៥** : អនុគណៈកម្មការនីមួយៗ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួង ដែលប្រធានជាអ្នកទទួលខុសត្រូវ។

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ប្រធានសភាពាណិជ្ជកម្មកម្ពុជា អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនឹងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧...សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូ ពិភាក្សាការងារជាមួយផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងសម្តេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧០អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

- យោងសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ និងសេចក្តីសំរេចលេខ ៤១ សសរ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារ ជាមួយវិស័យឯកជន
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារតំណាងអោយភាគីរាជរដ្ឋាភិបាល សំរាប់វិស័យ ០៧ ក្នុងក្របខ័ណ្ឌវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន។ ក្រុមការងារទាំង ០៧ នេះ ខាងផ្នែករាជរដ្ឋាភិបាល មានសមាសភាពដូចខាងក្រោម :

**ក. ក្រុមការងារផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្ម :**

| | | |
|---|---|---|
| ១- ឯកឧត្តម **ចន់ សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សហប្រធាន |
| ២- ឯកឧត្តម **ជា ស៊ាងហុង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អនុប្រធាន |
| ៣- ឯកឧត្តម **ម៉ុន អ៊ុយ** | រដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម **អេង ហួត** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៥- ឯកឧត្តម **គីម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- ឯកឧត្តម **កែវ ខេមរា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- ឯកឧត្តម **យិន គីមស៊ាន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម **ស្រ៊ុន ដារា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- ឯកឧត្តម **ភួយ សុខារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១០-ឯកឧត្តម **នូ គឿង** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១-ឯកឧត្តម **សួន សិទ្ធី** | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |

**ខ. ក្រុមការងារផ្នែកទេសចរណ៍ :**

| | | |
|---|---|---|
| ១- ឯកឧត្តម **ឡាយ ប្រហស្ស** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សហប្រធាន |
| ២- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម **សេង លឹមនៅ** | រដ្ឋលេខាធិការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម **ប្រាជ្ញ ស៊ុន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៥- ឯកឧត្តម **ស្វាង ម៉េងតា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **អ៊ុក សុជាតិ** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧- ឯកឧត្តម **សុខ សុទី** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

| | | |
|---|---|---|
| ៨- ឯកឧត្តម **ស៊ឹម ស៊ីឡេង** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- ឯកឧត្តម **កែវ សាផល** | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១០-ឯកឧត្តម **ខេព ហែន** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១១ ឯកឧត្តម **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |

## គ. <u>ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច-មធ្យម</u> :

| | | |
|---|---|---|
| ១- ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សហប្រធាន |
| ២- ឯកឧត្តម **ម៉ៅ ថាយលាង** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ សាន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៤- ឯកឧត្តម **គឿង សុភ័ណ្ឌ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥- ឯកឧត្តម **អ៊ឹង ភិរុន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦- ឯកឧត្តម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- ឯកឧត្តម **ទី តាយី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម **ឆា ជុប** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩- ឯកឧត្តម **តុច ចាន់កុសល** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០-ឯកឧត្តម **សយ សុខា** | អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១-ឯកឧត្តម **ស្វួន សិទ្ធី** | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១២-ឯកឧត្តម **អ៊ិត ណូឌី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣-ឯកឧត្តម **ស្រ៊ុន ទេវទណ្ណៈ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |

## ឃ. <u>ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច</u> :

| | | |
|---|---|---|
| ១- ឯកឧត្តម **គាត ឈន់** | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សហប្រធាន |
| ២- ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានទី១ |
| ៣- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥- ឯកឧត្តម **ហ៊ី សោភា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦- ឯកឧត្តម **គីម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- លោកជំទាវ **ច្រាក់ ចន្ថា** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

៨- ឯកឧត្តម **នុត សារអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៩- ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១០-ឯកឧត្តម **អ៊ឹង ប៊ុណ្ណារ៉ា** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១១-ឯកឧត្តម **មាស គឹមសុទិវ៉ា** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១២-ឯកឧត្តម **សូ ម៉ារ៉ា** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

## ខ. ក្រុមការងារផ្នែកសេវារាប់បញ្ចូលទាំងសេវាធនាគារ និងហិរញ្ញវត្ថុ :

១- ឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា សហប្រធាន

២- ឯកឧត្តម **ជា ប៉េងឈាង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៤- ឯកឧត្តម **ម៉ុម ស៊ីមុន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៥- ឯកឧត្តម **នៅ ភាស៊ី** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

៦- ឯកឧត្តម **ឯក វណ្ណឌី** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

៧- ឯកឧត្តម **សៀង ឡាប្រេស្ស** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៨- ឯកឧត្តម **សុខ ផេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៩- ឯកឧត្តម **ជា សែ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០-ឯកឧត្តម **អ៊ី ម៉ាន** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១១-ឯកឧត្តម **ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១២-ឯកឧត្តម **គីម សុភ័ណ្ណ** អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

១៣-លោក **តឹក រ៉េតសំរេច** ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

## គ. ក្រុមការងារផ្នែកថាមពល និងហេដ្ឋារចនាសម្ព័ន្ធ :

១- ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សហប្រធាន

២- ឯកឧត្តម **អ៊ិត ប្រាំង** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និថាមពល អនុប្រធាន

៣- ឯកឧត្តម **គង់ ហ៊ុនធារិទ្ធ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៤- ឯកឧត្តម **តាន់ ទុដ្ឋា** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៥- ឯកឧត្តម **លី អឿមឡាក់** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦- ឯកឧត្តម **នូច ហេង** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

| | | |
|---|---|---|
| ៧- ឯកឧត្តម កើត សារ៉េត | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- ឯកឧត្តម មួង សៅខន | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩- ឯកឧត្តម ជា ឆាយ | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០-ឯកឧត្តម អេង សួស្តី | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១១-ឯកឧត្តម សួន សិរិទ្ធី | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១២-ឯកឧត្តម ជា វ៉ាន់ដេត | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

ឆ- <u>ក្រុមការងារផ្នែកផលិតកម្មកែច្នៃសំរាប់នាំចេញ និងកិច្ចសំរួលពាណិជ្ជកម្ម</u> :

| | | |
|---|---|---|
| ១- ឯកឧត្តម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សហប្រធាន |
| ២- ឯកឧត្តម សួន ហេង | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម អូស្មាន់ ហាសាន | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦- ឯកឧត្តម ខ្លូត រ៉ាន់ឌី | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧- ឯកឧត្តម ខៀវ មុត | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម ប៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៩- ឯកឧត្តម ទាវ ជាង | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០-ឯកឧត្តម អ៊ុក សុខុន | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១-ឯកឧត្តម ឆា សុវត្ថា | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១២-ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

<u>ប្រការ ២</u> : វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនត្រូវប្រព្រឹត្តឡើងនៅរៀងរាល់ ០៦ ( ប្រាំមួយ ) ខែម្តង។ ក្នុងចន្លោះពេលមុនវេទិកាពេញអង្គ ក្រុមការងារនិមួយៗ មានភារកិច្ចសំខាន់ៗដូចតទៅ :

- ធ្វើការងារប្រទាក់ក្រឡាគ្នាជាមួយនឹងគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤
- ពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយដៃគូឯកជន ដើម្បីលើកឡើងនូវវិធានការដោះស្រាយ រាល់បាតុភាពអសកម្ម ដែលកើតមានក្នុងក្របខ័ណ្ឌវិស័យរបស់ខ្លួន អោយបានទាន់ពេលវេលា និងលើកជាសំណូមពរដោះស្រាយជូនស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីចាំបាច់។

- ពិនិត្យពិចារណាជាមួយផ្នែកឯកជនជាដៃគូ ក្នុងការលើកឡើងនូវរាល់គំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រ សំរាប់គាំទ្រលើកទឹកចិត្តបណ្តាក្រុមហ៊ុនកំពុងមានសកម្មភាព ក៏ដូចជាសំរាប់ទាក់ទាញការវិនិយោគ និងធុរកិច្ចថ្មីៗបន្ថែមទៀត មកកម្ពុជា។
- ធ្វើរបាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល ពីសកម្មភាពការងារ និងពីទិសដៅភារកិច្ចដែលត្រូវអនុវត្តជាបន្ត ដើម្បីមានជាមូលដ្ឋានសំរាប់ប្រមុខរាជរដ្ឋាភិបាលផ្តល់ជាអនុសាសន៍ នៅរៀងរាល់វេទិការាជរដ្ឋាភិបាល-វិស័យឯកជន។
- ទទួលដោះស្រាយរាល់ការចាំបាច់ផ្សេងៗទៀត ក្នុងក្របខ័ណ្ឌវិស័យរបស់ខ្លួន តាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល។

**ប្រការ ៣ :** ភារកិច្ចរបស់ក្រុមការងារនីមួយៗ មានវិសាលភាពគ្របដណ្តប់លើការងារដែលមានកំណត់ក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសំរេចនេះ។

**ប្រការ ៤ :** ប្រធានក្រុមការងារ "យ" ជាអ្នកសំរបសំរួលវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទីងដើរតួជាអគ្គលេខាធិការដ្ឋាន សំរាប់បំរើយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ ក្នុងពេលរង់ចាំការបង្កើតអគ្គលេខាធិការដ្ឋាននេះ ប្រធានក្រុមការងារនីមួយៗ អាចបង្កើតលេខាធិការដ្ឋាននៅតាមក្រសួង-ស្ថាប័នរបស់ខ្លួន ដោយប្រើប្រាស់មន្ត្រីរបស់ខ្លួនជាលេខាធិការ និងដោយប្រើប្រាស់ជាផ្លូវការនូវត្រារបស់ក្រសួង-ស្ថាប័នក្នុងកិច្ចទំនាក់ទំនងរាល់ការងារក្នុងក្របខ័ណ្ឌភារកិច្ច ដែលបានកំណត់ក្នុងប្រការ២ នៃសេចក្តីសំរេចនេះ។

**ប្រការ ៥ :** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាចំណុចកណ្តាលសំរាប់ធ្វើទំនាក់ទំនងអន្តរក្រុមការងារ និងសរុបរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

**ប្រការ ៦ :** សមាជិកក្រុមការងារនីមួយៗ ត្រូវចូលរួមប្រជុំអោយបានទៀងទាត់ តាមការអញ្ជើញរបស់ប្រធាន។ ប្រធានក្រុមការងារនីមួយៗ អាចអញ្ជើញថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ មកចូលរួមការងារបានក្នុងករណីចាំបាច់។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាង តាមការប្រគល់សិទ្ធិរបស់ប្រធាន។

សមាសភាពទាំងអស់នៃក្រុមការងារតាមផ្នែកនីមួយៗ មានសិទ្ធិចាត់តាំងរៀងៗខ្លួននូវសមាជិកបំរុង០១រូប សំរាប់ជួយការងារ ឬជំនួស នៅពេលអវត្តមាន។

**ប្រការ ៧ :** រាល់បទបញ្ញត្តិដែលមានពីមុនមក និងដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនឹងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ភ្នាក់ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សហប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចក្រុមព្រះ សហប្រធាន "ក.អ.ក"
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៨...សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្តឹងតវ៉ា ពាក់ព័ន្ធនឹងដីនៅតំបន់ដែនជំរកសត្វព្រៃរនាមដូនសំ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការគ្រប់រូបនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សំរេច</u>

<u>ប្រការ ១</u> : បង្កើតគណៈកម្មការចំរុះអន្តរក្រសួងមួយ ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្តឹងតវ៉ា ពាក់ព័ន្ធនឹងដីនៅតំបន់ដែនជំរកសត្វព្រៃរនាម ដូនសំ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានសមាសភាពខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម នុត សានាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម ឌិត ឥត្សីខត្តា | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | អនុប្រធាន |
| ៣-លោក សួន ស៊ីផាត | ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល និងជាប្រធានលេខាធិការដ្ឋានសុរិយោដីថ្នាក់ជាតិ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

| | | |
|---|---|---|
| ៤-លោក គុល ទីរៈ | ប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-លោក ឡុង សុខា | អនុប្រធាននាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-លោក សោម សាបាន | អនុប្រធាននាយកដ្ឋានទទួលបន្ទុកស្រាវជ្រាវ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៧-លោក កែន សេរីរដ្ឋា | អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | សមាជិក |
| ៨-លោក សុខ លីនណា | អនុប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងមហាផ្ទៃ | លេខា |

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលពាក់ព័ន្ធ ចុះពិនិត្យស្រាវជ្រាវ និងសំរបសំរួលបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋចំនួន ២.១០៣គ្រួសារ នៅឃុំអូររំដួល ឃុំពេជចិន្តា និងឃុំចក្រី ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលពាក់ព័ន្ធនឹងដីតំបន់ដែនជំរកសត្វព្រៃរនាមដូនស ព្រមទាំងខិតខំប្រមែប្រមូលឯកសារសំខាន់ៗ និងពត៌មានពិតជាក់ស្តែង ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : សមាជិកទាំងអស់របស់គណៈកម្មការត្រូវចូលរួមប្រជុំ និងចុះបំពេញភារកិច្ចតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងឯកឧត្តមអស់លោកដូចមានឈ្មោះក្នុងប្រការ១ មានភារកិច្ចទទួលអនុវត្តសេចក្តីសំរេចនេះអោយមានស្រិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៤

ឧបនាយករដ្ឋមន្ត្រី

ស ខេង

ចំលងជូន :

-ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
-ខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
"ដើម្បីជូននិងថ្វាយជ្រាប"
-ដូចប្រការ១និងប្រការ៤
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

" ...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព "

លេខ : ៧០០ បទ.[illegible]

ភ្នំពេញ ,ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤

## ប្រកាស

## ស្តីពីការ កែសម្រួល និងបន្ថែមលើការគ្រប់គ្រង បរិក្ខារវិទ្យុគមនាគមន៍ និង ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

~~~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៥ អ.ន.ក្រ ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០
ទូរសារ: (៨៥៥) ២៣-៤២៦៩៥២/៤២៦០១១
~~~~~~~~~~~~

- បានឃើញសេចក្តីសម្រេចលេខ ១៥៤ សសរ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពី ឋានានុក្រម គ្រប់គ្រងតម្លៃ
- ប្រកាសលេខ ២៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និង ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ
- យោងតាមការងារចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សំរេច

**ប្រការ១ :** ត្រូវបានបន្ថែម និងកែសម្រួលថ្លៃប្រើប្រាស់រលកអាកាសវិទ្យុក្នុង **ឧបសម្ព័ន្ធទី១** ចំណុចទី៨ និង**ឧបសម្ព័ន្ធទី២** នៃប្រកាសលេខ ២៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីថ្លៃនៃការប្រើប្រាស់បរិក្ខារ ទំនាក់ទំនងអន្តរជាតិ ( ក្នុងករណីមានការអនុញ្ញាតពិសេស ) ត្រូវបន្ថែម និងកែសម្រួលមានដូចជា:

**I-ឧបសម្ព័ន្ធទី១: ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ " បន្ថែម "**

| | |
|---|---|
| **ឃ/ VSATសំរាប់សម្លេង/ទិន្នលេខ ( សំរាប់ក្រុមហ៊ុនទូរស័ព្ទ )** | $ |
| -ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ | ៥០ |
| -ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតម្លើង | ១០០ |
| -តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ស្ថានីយ៍មួយគ្រឿងៗ | ២,០០០ |
| **ខ/ VSAT សំរាប់បញ្ជូនរូបភាពទូរទស្សន៍ក្នុងប្រទេស** | $ |
| -ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ | ៥០ |
| -ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតម្លើង | ១០០ |
| -តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ស្ថានីយ៍មួយគ្រឿងៗ | ១,០០០ |

**II-ឧបសម្ព័ន្ធទី២: ការទទួលស្គាល់បរិក្ខារវិទ្យុទូរគមនាគមន៍** (Type Approval Per Model) **" កែសម្រួល "**

| | | |
|---|---|---|
| -ទូរស័ព្ទចល័ត | ២,០០០ | (one time only) |
| -ទូរសារ (Facsimile machine) | ១,៥០០ | (one time only) |
| -បមាណើ (PABX) | ១,៥០០ | (one time only) |
| -ទូរស័ព្ទធម្មតា ឬ Wireless Phone | ១,៥០០ | (one time only) |
| -ជេជីង (Pager) | ១,០០០ | (one time only) |
| -បរិក្ខារវិទ្យុគមនាគមន៍ដទៃផ្សេងទៀត | ១,០០០ | (one time only) |
| -ប្រកាសទទួលស្គាល់ភ្នាក់ងារនាំចូលបរិក្ខារវិទ្យុគមនាគមន៍ | ៨០០ | (one time only) |
| -លិខិតនាំចូលបរិក្ខារវិទ្យុគមនាគមន៍ | ១០០ | (each time) |
| -វិញ្ញាបនប័ត្រប្រចាំឆ្នាំសំរាប់នាំចូល លក់ និង ជួសជុលបរិក្ខារវិទ្យុគមនាគមន៍ | ១០០ | |
| -វិញ្ញាបនប័ត្រប្រចាំឆ្នាំសំរាប់នាំចូល និង លក់ បរិក្ខារវិទ្យុគមនាគមន៍ | ៨០ | |
| -វិញ្ញាបនប័ត្រប្រចាំឆ្នាំសំរាប់លក់ និង ជួសជុលបរិក្ខារវិទ្យុគមនាគមន៍ | ៥០ | |

**ប្រការ២ :** ប្រកាសលេខ២៧២ បទ.ប្រក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៣ នៅមានតម្លៃជាធរមាន ។

**ប្រការ៣ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្ត-ក្រុង ក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៤ :** ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ូរ-ឃុន

<u>កន្លែងទទួល</u>

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ទីស្តីការ គណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងផែនការ

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៣ " ដើម្បីអនុវត្ត "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន**
**និងយុវនីតិសម្បទា**
លេខ ១១១ ស.អ.យ.

*រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤*

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់រូបសញ្ញា និងគំរូក្បាលលិខិត
# របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/សន/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- ពិនិត្យឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១.-** ត្រូវបានប្រកាសឱ្យប្រើប្រាស់អក្សរកាត់ និងរូបសញ្ញា សំរាប់សំគាល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានលក្ខណៈ និងអត្ថន័យដូចខាងក្រោម:

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អក្សរកាត់ : **ស.អ.យ.**
- អក្សរអង់គ្លេស Ministry of Social Affairs, Veterans and Youth Rehabilitation អក្សរកាត់ជាភាសាអង់គ្លេស : MOSVY

- របសញ្ញាក្រសួង : (ឧបសម្ព័ន្ធ ១)
  - ការរង្វង់មូលព័ទ្ធដោយស្លឹកឈើ ជារង្វង់ស្វែងក្របី មានសមាមាត្រស្មើនឹង ៥ ភាគ លើ ៦ ភាគស្លឹកឈើព័ទ្ធស្វែងក្របី ជានិមិត្តរូប ទឹកដី ព្រៃឈើ ធនធានធម្មជាតិ ដ៏សម្បូរបែបរបស់ព្រះរាជាណាចក្រកម្ពុជា
  - រង្វង់មូលជុំវិញខាងលើឈ្មោះក្រសួងជាភាសាខ្មែរ ខាងក្រោមឈ្មោះក្រសួងជាភាសាអង់គ្លេស ភ្ជាប់ដោយកំប្បាច់ពណ៌មាស តំណាងឱ្យភាពសហការយ៉ាងស្រុះស្រួល ក្នុងការអនុវត្តការងារ
  - ផ្ទៃក្នុងរង្វង់ពណ៌ខៀវផ្ទៃមេឃ តំណាងឱ្យសេរីភាព និងសន្តិភាព
  - ផែនទីព្រះរាជាណាចក្រកម្ពុជា ពណ៌បៃតងខ្ចី នៅចំកណ្ដាល តំណាងឱ្យទឹកដីដ៏ស្រស់បំព្រងនៃព្រះរាជាចក្រកម្ពុជា
  - រូបមនុស្សជាក្រាហ្វិក ៣ នាក់ ពណ៌ខៀវចាស់ តំណាងវ័យកណ្ដាល វ័យកុមារ វ័យចាស់ ស្ថិតនៅលើ ផែនទី ជានិមិត្តរូបនៃរូបសញ្ញាប្រជាពលរដ្ឋ ដែលនឹងទទួលនូវសេវាសង្គមកិច្ច សង្គ្រោះ ថែទាំ អភិវឌ្ឍន៍ និងសុខុមាលភាព និងជាតំណាងឱ្យភារកិច្ចស្នូលទាំង ៣ របស់ក្រសួងលើវិស័យ សង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទា
  - គំរូក្បាលលិខិត (ឧបសម្ព័ន្ធ ២) ។

**ប្រការ ២.-** ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋាន សង្គមកិច្ច និងយុវនីតិសម្បទា នាយកដ្ឋាន គ្រប់មន្ទីរ ខេត្ត-ក្រុង អង្គភាពស្ថាប័នក្រោម ឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។៚

**អ៊ិត សំហេង**

**ចំលងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
  ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សខេង ណាញ់
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

(ឧបសម្ព័ន្ធ ១ លេខ [illegible] អ.ស.យ.)

កំពស់ ៥ ភាគ




៦ ភាគ

ទទឹង

រដ្ឋមន្ត្រី

អ៊ិត សំហេង

(ឧបសម្ព័ន្ធ ២ លេខ ០១១ ស.អ.យ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ស.អ.យ. *រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០*

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambobodia. Fax/Phone: (855) 23 726086

Kingdom of Cambodia
Nation Religion King
*****

Ministry of Social Affairs, Veterans and Youth Rehabilitation
No. MOSVY

Phnom Penh, 200